EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

ព្រឹត្តិបត្រព័ត៌មាន

@ lbusdengage
lbschools.net/engage
LONG BEACH UNIFIED • SCHOOL • DISTRICT
Excellence and Equity





ព្រឹត្តិការណ៍ដ៏សំខាន់មួយ

នាយកសាលាបឋមសិក្សា Chavez គឺ Dr. Brenda Ocampo បុគ្គលិក និងមាតាបិតា បានបង្កើតព្រឹត្តិការណ៍គោរពសពមួយហៅ Día de los Muertos សំរាប់សិស្ស គ្រួសារ និងសហគមន៍។ អាសនៈ ដែលត្រូវបានរៀបចំឡើងដោយសិស្ស គឺដើម្បីផ្តល់កត្តិយសជូនគ្រួសារ វប្បធម៌ ប្រពៃណី និងការរំលឹកចងចាំ។

នៅក្នុងការចុះផ្សាយនេះ

- **វិទ្យាស្ថានភាពដឹកនាំគ្រួសារ**

  ថ្ងៃទី24 & 25 ខែតុលា

  យើងបានទទួលក្បែរ 70 គ្រួសារក្នុងមន្ទីរអប់រំ LBUSD ដែលចុះឈ្មោះ និងចូលរួមក្នុងវិទ្យាស្ថាន FLI។

- **ការអប់រំក្នុងនាមជាដៃគូ, ភាពស្ងប់ស្ងាត់ & ចិត្តមេត្តា និងបញ្ហាស្មុគស្មាញក្នុងពេលទទួលអាហារជុំគ្នាជាគ្រួសារ**

  ថ្ងៃទី28 & 29 ខែតុលា

  មានបុគ្គលិក និងមាតាបិតាក្បែរ 15 សាលាបឋមសិក្សា និងអនុវិទ្យាល័យដែលបានចូលរួមជាមួយគ្នា ដើម្បីទទួលការបង្ហាញអំពីគំរូសិក្ខាសាលា ពីគ្រូបង្វឹក។

- **អ្វីទៅជាការប្រឡងថ្មី ហៅ Amira ដើម្បីស្នង់វាស់មើលជំនាញអាន (សូមអានទំព័រ 4)**
- **ព័ត៌មានថ្មីៗក្នុងខែវិច្ឆិកាអំពីថវិកា (សូមអានទំព័រ 4)**
- **កាលវិភាគសំរាប់ការប្រជុំមាតាបិតា (សូមអានទំព័រ 2 & 5)**

រួមគ្នា យើងកំពុងតែកសាងអនាគតកាន់តែប្រសើរ – នៅក្នុង និងជាមួយសហគមន៍របស់យើង!

នៅពេលយើងឈានចូលដល់ខែវិច្ឆិកា គឺយើងខ្ញុំមានសេចក្តីអំណរគុណយ៉ាងពេញលេញចំពោះគ្រួសារ បុគ្គលិក និងដៃគូក្នុងសហគមន៍ ដែលធ្វើឱ្យមន្ទីរអប់រំរបស់យើងមានភាពកាន់តែមាំមួនឡើងជារៀងរាល់ថ្ងៃ។ ភាពជាដៃគូរបស់អ្នក – ទោះបីធ្វើតាមការស្ម័គចិត្តក្តី ការចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗក្តី ឬការគាំទ្រការសិក្សានៅតាមផ្ទះក្តី – គឺនៅតែបន្តការកែទម្រង់មកលើភាពស្វាគមន៍ និងទំនាក់ទំនងក្នុងសហគមន៍សាលារៀន។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះមាតាបិតាជាង 80 នាក់ ដែលបានចូលរួមជាមួយពួកយើងក្នុង វិទ្យាស្ថានភាពដឹកនាំគ្រួសារ ចំនួនពីរថ្ងៃ ដែលមានឥទ្ធិពលខ្លាំងនៅក្នុងខែតុលា។ ការបញ្ចេញកំលាំង គោលគំនិត និងការប្តេជ្ញាចិត្តរបស់អ្នកមកលើភាពដឹកនាំ គឺបានជំរុញលើកទឹកចិត្តរបស់ពួកយើងទាំងអស់។ ពួកយើងរង់ចាំស្តាប់ថា តើគ្រួសារជាច្រើននៅទូទាំងមន្ទីរអប់រំ កំពុងតែចូលរួមយ៉ាងដូចម្តេចដែរនៅក្នុងសិក្ខាសាលា ស្តីអំពី ការអប់រំក្នុងនាមជាដៃគូ, ភាពស្ងប់ស្ងាត់ & ចិត្តមេត្តា និងបញ្ហាស្មុគស្មាញក្នុងពេលទទួលអាហារជុំគ្នាជាគ្រួសារ នៅតាមសាលារបស់ពួកគេរៀងៗខ្លួន។ សូមអរគុណចំពោះមាតាបិតា និងបុគ្គលិក ដែលបានរៀបចំបង្កើតការប្រឹងប្រែងទាំងអស់នេះ និងរក្សាទុកនូវឱកាសសំរាប់ធ្វើទំនាក់ទំនង ការសន្ទនា និងការបង្ហាញភាពលូតលាស់។

រដូវនេះក៏រំលឹកប្រាប់ពួកយើងផងដែរអំពីឥទ្ធិពលនៃការបង្ហាញខ្លួន—សំរាប់គ្នាទៅវិញទៅមក និងសំរាប់សិស្សរបស់យើង។ វត្តមានសិក្សាដ៏ទៀងទាត់ គឺនៅតែជាមធ្យោបាយដ៏សំខាន់មួយជាងគេដែលដែលគ្រួសារអាចគាំទ្រមកលើលទ្ធផលជោគជ័យសំរាប់សិស្សបាន។ រៀងរាល់ថ្ងៃ គឺសំខាន់។ នៅពេលសិស្សបង្ហាញវត្តមានសិក្សា គឺពួកគេបង្កើនចំណេះ មានទឹកចិត្តខ្ពស់ និងធ្វើទំនាក់ទំនង ស្របដោយអត្ថន័យ។

សូមអរគុណចំពោះគ្រប់មធ្យោបាយ ដែលអ្នកបង្ហាញភាពជាដៃគូជាមួយយើងខ្ញុំ។

Dr. Lucy Salazar



ក្រុមសំរាប់ការចូលរួមរបស់មាតាបិតា



ក្រុមមាតាបិតានានា

បន្ថែមពីលើកម្មវិធី CAFE ក្រុមគ្រួសារ ក៏អាចចូលរួមក្នុងក្រុមមាតាបិតានានា ដែលបង្កើតចេញពីជំនាញឯកទេស និងបទពិសោធន៍ដែលពួកគេនាំមកតាមខ្លួន ក្នុងពេលទន្ទឹមគ្នានោះដែរ ក៏ផ្តល់នូវឱកាសដ៏មានអត្ថន័យសំរាប់ការដឹកនាំ ការរីកចំរើន និងការរៀនសូត្រផងដែរ។ ក្រុមមាតាបិតាទាំងនេះ នាំមាតាបិតាឱ្យជួបជុំគ្នា ដើម្បីរៀនសូត្រអំពីគំនិតផ្តួចផ្តើមរបស់មន្ទីរជាច្រើន ចែករំលែកមតិយោបល់ និងសហការគ្នា អំពីមធ្យោបាយក្នុងការជួយជ្រោមជ្រែងដល់សិស្សទាំងអស់។ តាមរយៈការចូលរួមក្នុងក្រុមនេះ គឺមាតាបិតាមិនត្រឹមតែពង្រឹងនូវជំនាញក្នុងការដឹកនាំរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយបង្កើតនូវអនាគតរបស់សាលា និងសហគមន៍នានារបស់យើងផងដែរ។





DISTRICT COMMUNITY ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសហគមន៍ប្រចាំមន្ទីរអប់រំ (DCAC) គឺមានសមាភាគជាតំណាងមាតាបិតាមកពីសាលា LBUSD ទាំងឡាយ ដែលឧបត្ថម្ភដោយមូលនិធិសហព័ន្ធ Title 1។ មាតាបិតា ត្រូវបានផ្តល់ឱកាសឱ្យចូលរួមពាក់ព័ន្ធ និងទទួលដំណឹងអំពីការសិក្សារបស់កូនពួកគេ។ មាតាបិតា ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានប្រជុំ ជាមួយមាតាបិតាផ្សេងៗទៀតនៅសាលារបស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃព្រហស្បត៍ ទី20 ខែវិច្ឆិកា តាម អនលាញ (Zoom) – ម៉ោង 5:30 ល្ងាច**



DISTRICT ENGLISH LEARNER ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសិស្សរៀនភាសាអង់គ្លេសប្រចាំមន្ទីរអប់រំ (DELAC) ជាវិធីសំរាប់ឱ្យមាតាបិតា អាចចូលរួមចំណែកក្នុងការអប់រំរបស់កូនពួកគេ នៅកំរិតមន្ទីរអប់រំបាន។ តំណាងរបស់ DELAC មាតាបិតាថ្នាក់ដឹកនាំមន្ទីរអប់រំ និងសមាជិកសហគមន៍ចូលរួមក្នុងការប្រជុំទាំងនេះ ជារៀងរាល់ខែ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី2 ខែធ្នូ នៅវិទ្យាល័យ Browning – ម៉ោង 9:30 ព្រឹក**



SANKOFA PARENT VILLAGE
LONG BEACH UNIFIED SCHOOL DISTRICT

ភូមិមាតាបិតាសាំងកូហ្វា (SPV) ជាសហគមន៍មើលថែនិងជួយផ្គត់ផ្គង់សម្រាប់មាតាបិតា និងអ្នកមើលថែរបស់កុមារអាមេរិកខ្មៅ។ មន្ទីរអប់រំ LBUSD ប្តេជ្ញាផ្តោតចិត្តទុកដាក់លើតម្រូវការពិសេសរបស់សមាជិកសហគមន៍របស់យើង និងចូលរួមតាមរបៀបដែលលើកកំពស់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។ **ការប្រជុំលកក្រោយ៖ ថ្ងៃច័ន្ទ ទី8 ខែធ្នូ នៅមជ្ឈមណ្ឌលធនធានគ្រូបង្រៀន (TRC) – ម៉ោង 5:30 ល្ងាច**



EDUCATIONAL OPPORTUNITIES for NATIVE AMERICANS and NATIVE ALASKANS
LONG BEACH UNIFIED SCHOOL DISTRICT

កម្មវិធីរបស់យើង ត្រូវបានរចនាបង្កើតឡើង ដើម្បីធានាថា សិស្សជនជាតិដើមអាមេរិក (AI)/ និងជនជាតិដើមអាឡាស្កា (AN) នៅក្នុងមន្ទីរអប់រំឡុងបីចមានឱកាសស្មើភាពគ្នា ក្នុងការទទួលបានការអប់រំ។ មាតាបិតា អាណាព្យាល បុគ្គលិកមន្ទីរ និងដៃគូនៅតាមសហគមន៍ ចូលរួមក្នុងការរៀបចំផែនការកម្មវិធីសិក្សា និងព្រឹត្តិការណ៍ផ្សេងៗ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី18 ខែវិច្ឆិកា ក្នុងបន្ទប់ប្រជុំធំ នៅវិទ្យាល័យ Browning – ម៉ោង 5:30 ល្ងាច**

សិក្ខាលាលាសំរាប់មាតាបិតា ដើម្បីរៀនសូត្រ រីកចំរើន និងពង្រឹងសិទ្ធិអំណាច រួមជាមួយគ្នា៖ នៅក្នុង និង ជាមួយ សហគមន៍

NEW

C.A.F.E.

ការចូលរួមសំរាប់សហគមន៍ និង គ្រួសារ

យើងខ្ញុំរំភើបរីករាយ សូមអញ្ជើញលោកអ្នក មកចូលរួមក្នុងសិក្ខាសាលាជាច្រើនវគ្គសំរាប់មាតាបិតា ហៅកាត់ថា C.A.F.E.។ សេចក្តីលម្អិតបន្ថែមនឹងផ្តល់ជូនក្នុងពេលឆាប់ៗនេះ!



PARENT UNIVERSITY

LONG BEACH UNIFIED SCHOOL DISTRICT



មានវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ដែលបានរចនាបង្កើតឡើង ដើម្បីជួយ និងផ្តល់សិទ្ធិអំណាចដល់ក្រុមគ្រួសារ ឱ្យក្លាយជាដៃគូសហការដ៏ពេញលេញ នៅក្នុងការអប់រំរបស់កូនពួកគេ។

មាតាបិតា និងអ្នកមើលថែ របស់ LBUSD ត្រូវបានស្វាគមន៍ឱ្យចូលរួម។ មានផ្តល់ជូនមធ្យោបាយយានជំនិះ ការមើលថែកុមារ ការជួយធ្វើលំហាត់កិច្ចការផ្ទះ ហើយនិងសេវាបកប្រែភាសា។





ចូលរួមជាមួយពួកយើងនៅ ថ្ងៃព្រហស្បត៍ ទី11 ខែធ្នូ 2025 នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច



វរសេនីយ៍ទោ ចូលនិវត្ត
Consuelo Castillo Kickbusch

វិទ្យាស្ថានដឹកនាំគ្រួសារ (FLI)

គោលបំណងចម្បងរបស់ FLI គឺបង្រៀនឪពុកម្តាយ និងអ្នកថែទាំ អំពីសិល្បៈ និងជំនាញ ភាពជាអ្នកដឹកនាំគ្រួសារ ដើម្បីគាំទ្រដល់សមិទ្ធផលសិក្សា និងភាពជោគជ័យក្នុងជីវិត។ FLI ក៏ប្តេជ្ញាចិត្តផងដែរ ក្នុងការបង្កើតក្រុមឪពុកម្តាយ និងអ្នកថែទាំដែលបានទទួលការបណ្តុះបណ្តាលជាពិសេស អោយមានចំណេះដឹង និងប្តេជ្ញាចិត្ត ដែលជួយគាំទ្រយ៉ាងសកម្មដល់កិច្ចខិតខំប្រឹងប្រែងរបស់សាលារៀន និងសហគមន៍ ដើម្បីផ្តល់ផលប្រយោជន៍ដល់កូនៗរបស់ពួកគេ និងលើកទឹកចិត្តដល់គ្រួសារដទៃទៀតឱ្យធ្វើដូចគ្នាដូច្នេះដែរ។

សិក្ខាសាលាអំពី ការអប់រំក្នុងនាមជាដៃគូ

សិក្ខាសាលាអំពី ការអប់រំក្នុងនាមជាដៃគូ "ភាពស្ងប់ស្ងាត់ និងចិត្តមេត្តា" គឺជាឱកាសមួយផ្សេងទៀតសំរាប់គ្រួសារ និងសាលាក្នុងមន្ទីរអប់រំ LBUSD គាំទ្រមកលើការសិក្សា សុខភាពផ្លូវចិត្ត និងភាពរាក់ទាក់នៃសិស្សរបស់ពួកគេ ខណៈពេលកំពុងតែពង្រីកនូវការធ្វើទំនាក់ទំនង ការតស៊ូមតិ និងភាពដឹកនាំ។







សារ និង ធនធានព័ត៌មាន របស់ LBUSD



ជួយជ្រោមជ្រែងដល់គ្រួសារដែលរងផលប៉ះពាល់ពីការពន្យារពេល កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP)

យើងដឹងហើយថា ការពន្យាពេលទទួលអត្ថប្រយោជន៍ SNAP នេះ អាចបន្ថែមភាពតានតឹងដល់គ្រួសារមួយចំនួន ដែលពឹងផ្អែកលើធនធានទាំងនេះ។ ចំពោះការធានាដល់សិស្សានុសិស្ស អាចទទួលបានអាហារ និងការជួយជ្រោមជ្រែង នៅតែជាអាទិភាពសម្រាប់មន្ទីរអប់រំរបស់យើង។

សាលាទាំងអស់របស់ LBUSD នៅតែបន្តផ្តល់អាហារពេលព្រឹក និងអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃដល់សិស្សានុសិស្ស ជារៀងរាល់ថ្ងៃសិក្សា។ សិស្សដែលបានចុះឈ្មោះចូលរៀនគួរ ក្នុងកម្មវិធីក្រៅម៉ោងសិក្សារបស់យើង ក៏ទទួលបានអាហារផងដែរ។

ជាពិសេស៖ បុគ្គលិកផ្នែកជំនួយសាលា មានវត្តមានដើម្បីភ្ជាប់ទំនាក់ទំនងសិស្ស និងក្រុមគ្រួសារជាមួយ ខាងឃ្លាំងអាហារនៅតំបន់ និងធនធានទាំងឡាយ ដែលមានមូលដ្ឋាននៅសហគមន៍។ មជ្ឈមណ្ឌលសុខុមាលភាពសំរាប់ថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទី8 អនុវិទ្យាល័យ និងវិទ្យាល័យទាំងអស់មានកន្លែងស្តុកអាហារនៅនឹងកន្លែងផ្ទាល់ (រហូតដល់អស់ស្តុក)។ ក្រុមគ្រួសារ និងសិស្សត្រូវបានស្វាគមន៍ក្នុងការមកទស្សនា ពេញមួយថ្ងៃសិក្សា។ មិនតម្រូវឱ្យមានការណាត់ជួបជាមុនទេ។

សំរាប់ការយល់ដឹងបន្ថែមអំពីធនធានសហគមន៍ គឺសូមទាក់ទងតាមទូរស័ព្ទ លេខ **211** ដើម្បីទទួលព័ត៌មានថ្មីៗអំពីការចែកផ្តល់អាហារ និងកម្មវិធីជំនួយផ្សេងៗ។

ចុចលើបណ្តាញនេះ ដើម្បីយល់ដឹងអំពីទីតាំងផ្សេងៗ។

ការប្រឡងសំរាប់សិស្ស ដែលមានសមត្ថភាពខ្សោយខាងផ្នែកអាន (Amira)

គំរោងក្នុងការប្រឡង គឺស្ទង់វាស់មើលជំនាញអានស្ទាត់ តាមការប្រើនិយាយភាសា ដូចជា៖ ភាពស្ទាត់ផ្នែកអានផ្ទាល់មាត់ ការបញ្ចេញសម្លេង និងការបកស្រាយពាក្យក្លែងក្លាយ។ ដោយវែកញែកមើលអំពីភាពពិតៗក្នុងការចំណាំមើលអាកប្បកិរិយារបស់សិស្សខាងផ្នែកអាន (ដូចជា៖ កំហុសឆ្គង រចនា ការផ្អាក និងការកែតំរូវដោយខ្លួនឯង ជាដើម) គឺគំរោងក្នុងការដាក់ប្រឡង ធ្វើការស្ទង់វាស់មើលអំពីអ្វីដែលសិស្សយល់ដឹង និងលើកបង្ហាញអំពីជំនាញជាក់លាក់ ដែលសិស្សត្រូវការបណ្តុះជាបន្ថែម។

ការដាក់ពាក្យជ្រើសរើសវិទ្យាល័យ

ថ្នាក់សិក្សាអនាគតកាលនៃឆ្នាំ2030!

យើងខ្ញុំមានសេចក្តីរីករាយក្នុងការគាំទ្រសិស្សថ្នាក់ទី 8 និងគ្រួសារ ខណៈពេលដែលអ្នកត្រៀមចូលរៀននៅតាមវិទ្យាល័យក្នុងរដូវស្លឹកឈើធ្លាក់ នៃឆ្នាំ2026។

- **ការដាក់ពាក្យជ្រើសរើសវិទ្យាល័យ គឺបើកទទួលនៅថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2025 តាមការប្រើក្នុងប្រព័ន្ធ ParentVUE។**
- **សិស្សថ្មី ឬ សិស្សរស់នៅ ឡុងប៊ីច ដែលត្រឡប់មកមន្ទីរអប់រំ LBUSD វិញ គឺអាចផ្ញើបញ្ជូនឯកសារតាម អនឡាញ បានចាប់ផ្តើមនៅថ្ងៃទី13 ខែតុលា ឆ្នាំ2025 ដើម្បីទទួលបាននូវសិទ្ធិជំរើសវិទ្យាល័យ។**

<u>ចុចនៅទីនេះ ដើម្បីទទួលបាននូវធនធានផ្សេងៗ ដែលជាការណែនាំសំរាប់អ្នកចាត់ចែងធ្វើតាមវិធានការជាបន្តបន្ទាប់។</u>

<u>ការិយាល័យជំរើសវិទ្យាល័យ</u>
តាមទូរស័ព្ទ៖ (562) 997-8306 ឬ
HSMSChoicehelp@lbschools.net

ចូលរួមជាមួយយើងខ្ញុំក្នុងទស្សនកិច្ចវិទ្យាល័យ






យើងខ្ញុំសូមថ្លែងអំណរគុណដល់គ្រួសាររបស់យើងទាំងអស់ចំពោះជំនួយគាំទ្រ និងការតាំងប្តេជ្ញាចិត្តរបស់អ្នកមកលើសិស្សក្នុងមន្ទីរអប់រំ LBUSD របស់យើង។ សូមជូនពរឱ្យបានទទួលនូវសុត្ថិភាព និងភាពរីករាយនៅពេលសំរាកក្នុងពិធីបុណ្យរំលឹកគុណ។

ព័ត៌មានថ្មីៗអំពីថវិកា

យើងខ្ញុំនឹងចែកផ្តល់ព័ត៌មានធម្មតា និងដ៏សំខាន់ថ្មីៗប្រចាំខែអំពីថវិការបស់មន្ទីរអប់រំ។ យើងខ្ញុំតាំងការប្តេជ្ញាចិត្តក្នុងការបង្ហាញតម្លាភាព និងជំរាបជូនអ្នកអំពីឱនភាពថវិកាដ៏ធំធែង ដែលយើងកំពុងជួបប្រទះ និងការប្រើវិធានការដើម្បី "កែសំរួល" ក្នុងការដោះស្រាយបញ្ហាក្នុងមន្ទីរអប់រំ ដែលប៉ះពាល់មកលើភាពស្រកចុះនៃការចុះឈ្មោះរបស់សិស្ស។ សូមលៃលកបញ្ជូនសិស្សចូលសាលារាល់ថ្ងៃ និងត្រៀមខ្លួនទទួលការសិក្សាដែលជាមធ្យោបាយស្របដោយប្រសិទ្ធិភាពជាងគេក្នុងការបង្កើនលទ្ធផលសិក្សាសំរាប់សិស្ស និងការដោះស្រាយបញ្ហាខ្វះខាតថវិកា។ សូមត្រឡប់មកធ្វើការតាមដានឡើងវិញឱ្យបានញឹកញាប់អំពីព័ត៌មានថ្មីៗ ដោយមូលហេតុថា ការយកចិត្តទុកដាក់ និងការយល់ដឹងរបស់អ្នក គឺមានសារសំខាន់ដែលយើងធ្វើការស្វែងយល់អំពីដំណើរការនេះរួមគ្នា។

<u>lbschools.net/budget.</u>

ព័ត៌មានថ្មីៗអំពីក្រុមប្រឹក្សាភិបាលរបស់មន្ទីរអប់រំ LBUSD



Click on the image

ព្រឹត្តិការណ៍ជាបន្តបន្ទាប់ និង ឱកាសធ្វើទំនាក់ទំនង

សូមឆែកមើលនៅតាមចំណែកនេះរាល់ខែអំពីសិក្ខាសាលា ការប្រជុំមាតាបិតា និងព្រឹត្តិការណ៍ផ្សេងៗ ដែលនឹងរៀបចំផ្តល់ជូនជាបន្តបន្ទាប់។ សូមកុំភ្លេចអំពីឱកាសរៀន រាក់ទាក់ស្គាល់គ្នា ទទួលការសិក្សា និងធ្វើទំនាក់ទំនងជាមួយសហគមន៍សាលារៀនរបស់យើង។

ខែវិច្ឆិកា

S	M	T	W	TH	F	S
						1 កម្មវិធី Sankofa ថ្ងៃសៅរ៍
2	3	4 សិក្ខាសាលា Parent University (អនឡាញ) 6:00ល្ងាច	5 ប្រជុំក្រុមប្រឹក្សាភិបាលអប់រំ 5ល្ងាច	6 សិក្ខាសាលា Parent University នៅវិទ្យាល័យ Browning 5:30pm ការស្ទង់វាស់មើលរោគរបេង នៅវិទ្យាល័យ Browning ម៉ោង 4:00 ល្ងាច	7	8 កម្មវិធី Sankofa ថ្ងៃសៅរ៍
9	10 ប្រជុំ Sankofa សំរាប់គ្រួសារអាមេរិកាំង ខ្មៅ នៅ TRC 5:30ល្ងាច	11 VETERANS day	12 ប្រជុំ CAC នៅមជ្ឈមណ្ឌលធនធានគ្រូបង្រៀន 6:00ល្ងាច	13	14	15 កម្មវិធី Sankofa ថ្ងៃសៅរ៍
16	17	18 ប្រជុំ EONA នៅវិទ្យាល័យ Browning 5:30ល្ងាច	19 ប្រជុំក្រុមប្រឹក្សាភិបាលអប់រំ 5ល្ងាច	20 ប្រជុំ DCAC 5:30-6:30 ល្ងាច អនឡាញ	21 សិក្ខាសាលា C.A.F.E. នៅវិទ្យាល័យ Browning 9:30ព្រឹក	22
23	24 thanksgiving	25	26	27 Break!	28	29
30						

Parent University



C.A.F.E.



DCAC



EONA



DELAC

